**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# មេរៀន៤ សំខាន់ ដែលទទួលបានពី
## «ជម្លោះព្រំដែនខ្មែរ-ថៃ ២០២៥»

**ភ្នំពេញថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥**

**ដោយៈ ម៉ៅ សុគន្ធា**

ទំនាក់ទំនងរវាង កម្ពុជា និង ថៃ មានអាយុកាល៧៥ឆ្នាំហើយ គិតត្រឹមឆ្នាំ២០២៥នេះ។ ជាមួយគ្នានោះ កម្ពុជា និងថៃ ជាប្រទេសដែលមានព្រំដែនជាប់គ្នាប្រវែង ៨១៧គីឡូម៉ែត្រ ដោយមានវប្បធម៌ និងប្រពៃណី ស្រដៀងគ្នា ហើយក៏ជាអ្នកជិតខាងដែលតែងដោះដូរពាណិជ្ជកម្មគ្នាទៅវិញទៅមក។

បើទោះបីជាយ៉ាងណាក៏ដោយ ប្រទេសជាប់ព្រំប្រទល់មួយនេះ កន្លងមក ក៏មានទំនាស់ជាច្រើន ទៅលើប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី និង ព្រំដែន ពិសេសការទាមទារនូវភាពជាម្ចាស់លើប្រាសាទបុរាណមួយចំនួនដែលត្រូវបានដាក់ចូលជាបេតិកភណ្ឌពិភពលោកដោយភាគីកម្ពុជា ។ ភាគីថៃយល់ឃើញ និងលើកឡើងថា រាល់ប្រាសាទ និងទឹកដីទាំងនោះ ជាទឹកដីរបស់ខ្លួន ហើយដូនតាខ្លួនជាអ្នកសាងសង់។ ហេតុនេះ ភាគីថៃតែងចិញ្ចឹមចិត្តចង់បានបេតិកភណ្ឌពិភពលោកទាំងនោះជារបស់ខ្លួន ហើយតែងបង្ករជម្លោះជារឿយៗនៅតាមព្រំដែន។

កាលពីព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ មានការផ្ទុះជម្លោះជាថ្មីម្តងទៀត ដែលកើតឡើងក្បែរតំបន់មុំបី ឬចុងបូក ដែលជាចំនុចប្រសព្វកម្ពុជា-ថៃ-ឡាវ ដោយសារតែទាហានថៃ បានធ្វក់បាញ់ទាហានកម្ពុជាម្នាក់ស្លាប់ដោយមិនដឹងខ្លួន។ បន្ទាប់មក កម្តៅនៃទំនាស់បានឈានដល់ការបិទព្រំដែន ដែលចាប់ផ្តើមដោយភាគីថៃ និងបានគម្រាមបិទការនាំចូលបន្លែ ត្រី សាច់ ប្រេងសាំង-ម៉ាស៊ុត ប្រព័ន្ធអ៊ីនធើណិត និងអគ្គីសនី...ជាដើម។ រហូតដល់ព្រឹកថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ មានការផ្ទុះអាវុធទ្រង់ទ្រាយធំនៅតាមបន្ទាត់ព្រំដែន ត្រង់ចំណុចតំបន់ជម្លោះ ដោយចាប់ផ្តើមក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ(អូស្មាច់ និងប៉ោយប៉ែត) តំបន់ប្រាសាទតាក្របី ប្រាសាទតាមាន់ធំ តំបន់មុំបី តំបន់ភ្នំខ្មោច តំបន់ភ្នំទ្រព្យ ប្រាសាទព្រះវិហារ(តំបន់៥មករា ចំការចេក) ជប់គគីរ ថ្មដូន វាលឥន្ទ្រីយ៍ ប្រកអានសេះ តំបន់ថ្មដា កោះគុជ និងកោះឆាង...ជាដើម ដែលការបង្ករនិងបង្កើនសមរភូមិដោយភាគីថៃ។ ចាប់តាំងពីថ្ងៃទី២៤ កក្កដា រហូតដល់ថ្ងៃទី២៨ ខែកក្កដានេះ ការចល័តរថពាសដែក ការប្រើប្រាស់អាវុធ និងកងកម្លាំងទាហាន នៅតាមទីតាំងដែលបានបើកការវាយប្រហារដោយភាគីថៃកាន់តែកើនឡើង រហូតឈានដល់ការប្រើប្រាស់យន្តហោះចម្បាំងF-16 គ្រាប់បែកចង្កោម ផ្សែងពុល និងយន្តហោះដ្រូនអត្តឃាដ (សុជាតា, ២០២៥) រីឯ ភាគីកម្ពុជា បាន

ត្រឹមការពារខ្លួន និង បូរណភាពដែនដី តាមរយៈការតបតដោយការប្រើកម្លាំងទ័ព និងអាវុធ ដែលស្របទៅតាមច្បាប់សង្គ្រាម និងច្បាប់អន្តរជាតិ តែប៉ុណ្ណោះ។

ក្នុងអំឡុងពេលនៃជម្លោះ យើងឃើញថា មិនត្រឹមតែជា ជម្លោះដោយប្រើអាវុធ និងកងកម្លាំងទាហានប៉ុណ្ណោះទេ ក្នុងនោះមានរឿងធំៗចំនួនបួន ដែលឱ្យចាប់អារម្មណ៍ ដូចជា៖

ទីមួយ ព័ត៌មានវិទ្យា និងបច្ចេកវិទ្យា បានដើរតួនាទីយ៉ាងសំខាន់។ នៅតាម*បណ្តាញសង្គម* ទាំងកម្ពុជា និងថៃ បានបើកសមរភូមិវាយប្រហារគ្នាទៅវិញទៅមកក្នុងផ្នែកព័ត៌មានវិទ្យា ហើយមានសន្ទុះយ៉ាងខ្លាំងក្លាផងដែរ។ នៅក្នុងការប្រយុទ្ធក្នុងសមរភូមិបណ្តាញសង្គម មានការបង្កើតព័ត៌មាន ទាំងជាលក្ខណៈផុសទ័រ វីដេអូ អត្ថបទវិភាគ និងតាមរយៈការបញ្ចេញព័ត៌មាននៅលើទំព័រហ្វេសប៊ុកជាតិ និងអន្តរជាតិធំៗ ដោយប្រើប្រាស់ភាសាជាច្រើនដូចជា ភាសាខ្មែរ ភាសាថៃ ភាសាចិន ភាសាអង់គ្លេស ភាសាជប៉ុន ភាសាកូរ៉េ និងភាសាមូស្លីម...ជាដើម។ ទន្ទឹមនឹងការវាយប្រហារគ្នាលើបណ្តាញសង្គម ទាំងកម្ពុជា និងថៃ ក៏ត្រូវរងគ្រោះក្នុងការបំផ្លាញគ្នាទៅវិញទៅមក។ សមត្ថភាពដែលជាទីចាប់អារម្មណ៍នៅចំណុចនេះ គឺសមត្ថភាពបង្កើតបណ្តាញសង្គម ការពារ វាយប្រហារ និងសមត្ថភាពបង្កើតមាតិកាព័ត៌មាន មិនថាជាព័ត៌មានពិត ឬបំភ្លៃ។ ព័ត៌មានទាំងនេះបង្កើតឡើងក្នុងគោលបំណង បកស្រាយ បង្ហាញ វាយប្រហារ និងដើម្បីទប់ទល់ស្ថានភាព។ ទន្ទឹមនោះ បើទោះជាកម្ពុជា ទទួលរងការវាយប្រហារយ៉ាងសន្ធាប់ពីភាគីថៃ ប៉ុន្តែ កម្ពុជាបានទប់ទល់យ៉ាងរឹងមាំដោយប្រើកម្លាំង ទីតាំងភូមិសាស្ត្រ និងក្បួនសឹករបស់ខ្លួន។ អ្វីដែលយើងកត់សម្គាល់ពីភាគីថៃ ក្រៅពីកម្លាំងទ័ពច្រើនជាងគេបានប្រើប្រាស់សព្វាវុធ និងយុទ្ធោករណ៍ទំនើបៗជាច្រើនក្នុងការវាយប្រហារ។ នៅទីនេះ ***បច្ចេកវិទ្យា និងជំនាញក្នុងការប្រើប្រាស់ និងជួសជុល ដើរតួនាទីសំខាន់*** ហើយអ្វីដែលរិតតែសំខាន់ជាងនេះ គឺបច្ចេកវិទ្យា និងវិធីសាស្ត្រទប់ទល់។ ម្យ៉ាងវិញទៀត ការយកការណ៍ពីស្ថានភាពនៅកម្ពុជាពីភាគីថៃ បានធ្វើឡើងតាមរយៈការប្រើប្រព័ន្ធGPSដាក់តាមខ្លួនជនបង្កប់ powerbank ការបង្ហោះរូបភាព និងវីដេអូ ដែលមានភ្ជាប់ទីតាំង និងប្រព័ន្ធទូរស័ព្ទ(smart) ....ជាដើម ដែលបង្ហាញថា កម្ពុជាត្រូវការឧបករណ៍ត្រួតពិនិត្យ និងបច្ចេកវិទ្យាបន្ថែមដើម្បីទប់ទល់នឹងស្ថានការណ៍បែបនេះ។

ទីពីរ នៅថ្ងៃទី២៤ ខែកក្កដានេះ ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ មានចំនួន ២០៣, ៧០៦នាក់ ហើយបើគិតត្រឹម៥ថ្ងៃនៃការប្រយុទ្ធគ្នានេះ មានពលករខ្មែរសរុបជិត ៤០ម៉ឺននាក់ ត្រឡប់មកកាន់កម្ពុជាវិញ ខណៈពេលដែលពលករកម្ពុជាធ្វើការនៅប្រទេសថៃ មានចំនួនប្រមាណ ១លាន ២សែននាក់ (ឈុនហ៊ាត, ២០២៥))។ ដើម្បីឆ្លើយតបហ្នឹងការមកដល់នៃពលករខ្មែរពីប្រទេសថៃ រាជរដ្ឋាភិបាលបានរៀបចំត្រៀមការងារជាច្រើន ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានត្រៀមខ្លួនបណ្តុះបណ្តាលជំនាញ និងស្វែងរកការងារជូន។

ទីបី យើងក៏ឃើញថា ប្រជាជនខ្មែរ ដែលនៅតាមបណ្តាប្រទេសជាច្រើនដូចជា អាម៉េរិក និងរដ្ឋផ្សេងៗទៀតជាច្រើន អូស្ត្រាលី ជប៉ុន ចិន កាណាដា ប្រមូលផ្តុំគ្នានៅតាមមុខស្ថានទូត លើកទង់ជាតិកម្ពុជា ជាមួយនឹងសម្រែកតវ៉ា និងស្នើសុំយុត្តិធម៌ដល់កម្ពុជា ។ប្រយោគដែលពួកគាត់ស្រែកឡើង៖ «សូមផ្តល់យុត្តិធម៌ដល់កម្ពុជា» «ថៃជាអ្នកចាប់ផ្តើមការវាយប្រហារមកលើកម្ពុជាមុន» «កម្ពុជាត្រូវការសន្តិភាព» «កម្ពុជាមិនត្រូវការសង្គ្រាមទេ».....។ ជាមួយ

គ្នានោះ ក្រោយមានការបើកការវាយប្រហារពីភាគីថៃ ប្រជានដែលនៅសងខាងព្រំដែន ទាំងកម្ពុជា និងថៃ ត្រូវបានជម្លៀសទៅកាន់ទីតាំងសុវត្ថិភាព ។ ក្នុងនោះ ជនភៀសសឹកកម្ពុជា គិតត្រឹមថ្ងៃទី២៧ ត្រូវបានជម្លៀសទៅកាន់ទីតាំងសុវត្ថិភាព និងផ្ទះសាច់ញាតិ មានចំនួន៤ខេត្តៈ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ដែលមានចំនួនប្រជាជនសរុបចំនួន ៣៩ ៨២៨គ្រួសារ ស្មើនឹង ១៣៤ ៧០៧នាក់រាប់ទាំងកុមារ ស្ត្រីមានផ្ទៃពោះ ចាស់ជរា និងជនពិការ។ ចំពោះស្ថានភាពមួយនេះ ប្រជាជនខ្មែរជាច្រើន បានចេញមុខព្រួតដៃគ្នា ប្រមូលធនធាន និងចែករំលែក រួមជាមួយហ្នឹងការលះបង់ទាំងពេលវេលា ទ្រព្យសម្បត្តិផ្ទាល់ខ្លួន កម្លាំង និងញើសឈាមចែករំលែកដល់ជនភៀសសឹក និងយុទ្ធជន។ ជាមួយគ្នានោះ ក៏បានឃើញ សាធារណៈជនមួយចំនួនតូច ដែលមិនមានការយកចិត្តទុកដាក់ និងមិនបានយល់ពីស្ថានភាពរឹករក្នុងប្រទេសទាល់តែសោះ ហើយយល់តែសេចក្ដីសុខផ្ទាល់ខ្លួន ដែលបង្ហាញពីភាពអាត្មានិយម ។

ទីបួន ផលិតផលក្នុងស្រុកនៅមិនទាន់អាចជំនួសផលិតផលដែលនាំចូលពីថៃ និងផលិតផលប្រទេសផ្សេងទៀត ពិសេសផលិតផលម្ហូបអាហារ និងសម្ភារៈប្រើប្រាស់។ ក្នុងឆ្នាំ២០២៤ ផលិតផលម្ហូបអាហារ និងផលិតផលប្រើប្រាស់ចាំបាច់ដែលកម្ពុជានាំចូលពីប្រទេសថៃមានដូចជា៖១).បន្លែ ៥០,៧២លានដុល្លារ ២).សាច់ ត្រី និងគ្រឿងសមុទ្រ ១២២.៨៤លានដុល្លារ ៣).ផលិតផលស៊ុត ទឹកដោះគោ ៧៧,៣៦លានដុល្លារ ៤).ស្ករសនិងគ្រឿងដំណាប់ ៧៤,៤៦លានដុល្លារ និង ៥).ភេសជ្ជៈ ៤២៤,៦០លានដុល្លារ រួមទាំងទំនិញផ្សេងៗទៀត សរុប ៩២៣០លានដុល្លារអាម៉េរិក (Economy, 2025)។ ហេតុនេះ យើងឃើញថា កម្ពុជានៅមានតម្រូវការច្រើនលើទំនិញចាំបាច់ បើទោះជារាជរដ្ឋាភិបាលបានព្យាយាមជំរុញយ៉ាងណាក៏ដោយ។

ជាអនុសាសន៍ ចំពោះមេរៀនទាំង៤នេះ កម្ពុជាគួរពិចារណា និងយកចិត្តទុកដាក់ ដូចខាងក្រោម៖

១.ផ្នែកព័ត៌មានវិទ្យា និង បច្ចេកវិទ្យា៖

- គួរមានការត្រៀមខ្លួនក្នុងវិស័យព័ត៌មានវិទ្យា និងបច្ចេកវិទ្យា ទាំងការបង្កើតថ្មី ការថែទាំ ការការពារពីការលួចគ្រប់គ្រងពីសត្រូវឱ្យបានរឹងមាំ និងការវាយបកទៅលើសត្រូវ
- គួរបញ្ជូនជនដែលមានទេពកោសល្យក្នុងស្រុកទៅសិក្សានៅប្រទេសដែលមានជំនាញនេះខ្លាំងដូចជា ឥណ្ឌា អាម៉េរិក កាណាដា សិង្ហបុរី និងអូស្ត្រាលី ...ជាដើម ហើយបើកជាមជ្ឈមណ្ឌលបច្ចេកវិទ្យា និង ព័ត៌មានវិទ្យាជំនាញមួយនៅកម្ពុជា និងឱ្យជនបង្គោលទាំងនោះបណ្ដុះបណ្ដាលបន្ត
- គួរមានកញ្ចប់ត្រៀមមួយដោយឡែក ដើម្បីផ្ដត់ផ្គង់ពួកគាត់ទាំងសម្ភារៈ បរិក្ខារ និងការឧបត្ថម្ភជាពិសេស

២.ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ៖

- រកមធ្យោបាយបណ្តុះបណ្តាលជំនាញដែលប្រើពេលតិចជាងមុន ឬ គួរបង្កើតឱកាសការងារក្រៅម៉ោងឱ្យបានច្រើន ដើម្បីឱ្យពួកគាត់អាចមានពេលវេលារៀនជំនាញផង និងរកចំណូលផង(បន្ថែមលើគោលនយោបាយ ១,៥លាននាក់ ដែលរាជរដ្ឋាភិបាលកំពុងអនុវត្ត)
- ផ្តល់តម្លៃដល់បុគ្គលិកជំនាញ(វិជ្ជាជីវៈ និងក្រមសិលធម៌ការងារ) ជាជាងបុគ្គលិកដែលប្រើតែកម្លាំង ដើម្បីឱ្យពួកគាត់ងាកទៅចាប់យកការបណ្តុះបណ្តាលជំនាញត្រឹមត្រូវ និងមានវិជ្ជាជីវៈការងារប្រកបដោយស្តង់ដារ
- កំណត់ជំនាញអាទិភាព ចំនួន៥ ដែលអាចបណ្តុះបណ្តាលរយៈពេលខ្លី ចាប់ពី១ខែ ៣ខែ ៦ខែ ១ឆ្នាំ ឬ២ឆ្នាំ(រៀនចប់អាចប្រើការបាន)៖ ១.ជំនាញបច្ចេកវិទ្យា ២.ព័ត៌មានវិទ្យា ៣.របៀបរស់រានក្នុងសង្គ្រាម ឬមានអាសន្ន ៤.ជំនាញផលិត និងកែច្នៃ ម្ហូបអាហារ(ស្បៀង) (សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងចាំបាច់ក្នុងគ្រាមានអាសន្ន) ៥.ជំនាញផលិត ថែទាំ និងជួសជុល សម្ភារៈ-បរិក្ខារ(ដែលប្រើប្រាស់ប្រចាំថ្ងៃ និងចាំបាច់ក្នុងគ្រាមានអាសន្ន)។ បន្ទាប់មកបញ្ជូនជនបង្គោលទៅសិក្សានៅប្រទេសណាដែលមានជំនាញពិតប្រាកដ ហើយជនដែលទទួលបានការបណ្តុះបណ្តាល គប្បីគោរពវិជ្ជាជីវៈ ក្រោយបណ្តុះបណ្តាលចប់ ត្រូវតែបណ្តុះបណ្តាលប្រជាជនខ្មែរបន្តនៅក្នុងប្រទេស។

៣.ការអប់រំស្មារតី៖

- បណ្តុះស្មារតី (កុមារ) ឱ្យមានស្មារតីស្នេហាជាតិ ដែលអាចចាប់ផ្តើមពីថ្នាក់មតេយ្យ តែមិនមែនជាការរើសអើង និងស្អប់ខ្ពើមជាតិសាសន៍ដទៃ
- បណ្តុះស្មារតី (កុមារ) ឱ្យចេះស្គាល់ពីគ្រាមានទុក្ខ ចេះចែករំលែកទុក្ខ យល់ពីទុក្ខលំបាកអ្នកដទៃ និង ចេះជួយអាសារគ្នា ដែលនេះគឺជាតួនាទីសំខាន់របស់ឪពុកម្តាយ ក្រុមគ្រួសារ និងសង្គម
- បណ្តុះស្មារតី (កុមារ) ឱ្យចេះ និងមានទម្លាប់សាមគ្គីគ្នា កុំមានចិត្តចង់បានរបស់អ្នកដទៃ ស្អប់ភាពអាត្មានិយម
- បណ្តុះស្មារតី គោរពតាមការណែនាំរបស់រាជរដ្ឋាភិបាល សមត្ថកិច្ច និងអាជ្ញាធរ

៤.ការផលិត(SME) ក្នុងដំណាក់កាលនេះ យើងអាចចាប់ផ្តើមពង្រឹងការផលិត ផលិតផលក្នុងស្រុកឱ្យបានច្រើន ជាពិសេសផលិតផលម្ហូបអាហារ និងផលិតផលប្រើប្រាស់ប្រចាំថ្ងៃសិន តាមរយៈ៖

- វិនិយោគលើបរិក្ខារខ្នាតតូច មធ្យម និងខ្នាតធំ លើដំណើរកាចង្វាក់ផលិតកម្ម សម្បកវេចខ្ចប់ និងដំណើរការវេចខ្ចប់
- វិនិយោគលើថាមពលដែលមិនមែនអគ្គីសនី ដូចជា ថាមពលព្រះអាទិត្យ .....ដែលអាចកាត់បន្ថយថ្លៃដើមផលិត
- សម្របសម្រួលដំណើរការនីតិវិធីច្បាប់ក្នុងការចុះបញ្ជី(សេវាសាធារណៈ)សិប្បកម្មផលិត និងគាំទ្រនូវការធ្វើពិសោធន៍គុណភាពឱ្យបានល្អ ស្តង់ដា និងងាយស្រួល

- មន្ត្រីជំនាញលើការពិនិត្យគុណភាព(QA និង QC) និងការផលិត គួរពង្រឹងការបណ្តុះបណ្តាលឱ្យបានទូលំទូលាយដល់អ្នកផលិត ឱ្យបានត្រឹមត្រូវតាមស្តង់ដារ
- វិនិយោគកាន់តែទូលំទូលាយ ដល់ការផ្តល់កម្ចីដើមទុនក្នុងវិស័យSME ប៉ុន្តែភ្ជាប់ជាមួយនឹងការត្រួតពិនិត្យលើផែនការអាជីវកម្មឱ្យបានហ្មត់ចត់ ការតាមដាន ការវាយតម្លៃ និងជួយដោះស្រាយបញ្ហាដល់អ្នកខ្ចី។

**ចប់**!

# ឯកសារយោង

១.អ្នកនាំពាក្យនៃក្រសួងការពារជាតិ លោកស្រី ម៉ាលី សុជាតា, ២០២៥, សន្និសីទសារព័ត៌មាន ស្តីពីសភាពការណ៍ ថ្ងៃទី២៧ និង ២៨ ខែកក្កដា ឆ្នាំ២០២៥ , Telegram post , https://t.me/khpublic_document/13007

២.ឈុនហ៊ាត, ២០២៥, https://economy.ams.com.kh/economic/news/cambodia-has-approximately-1.2-million-migrant-workers-working-in-thailand

៣. Economy, 2025, Trading Economics. *Thailand exports to Cambodia*. https://tradingeconomics.com/thailand/exports/cambodia